**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករមូលបត្រកម្ពុជា**

**និយ័តករបរធនបាលកិច្ច**

លេខ:...៧.សសក...........

ថ្ងៃ ពុធ ១៣រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០២២

# គោលការណ៍ណែនាំរួម
# ស្ដីពី
# ការចុះបញ្ជី និងការស្នើសុំការអនុញ្ញាតបន្ថែមរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសនៃគម្រោងវិនិយោគរួម និងភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីបរធនបាលកិច្ច, អនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនិយ័តករ និងអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ ២០១៩ ស្ដីពីការចុះបញ្ជីបរធនបាលកិច្ច, ប្រកាសលេខ ០០៣/១៨ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការផ្ដល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម, ប្រកាសលេខ ០០២/១៨ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការទទួលស្គាល់ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ និងប្រកាសលេខ ០០៣ អ.ស.ហ.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្ដីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត និងដើម្បីកំណត់លក្ខខណ្ឌនៃការចុះបញ្ជី និងការស្នើសុំការអនុញ្ញាតបន្ថែម ព្រមទាំងកាតព្វកិច្ចផ្សេងៗ របស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសនៃគម្រោងវិនិយោគរួម និងភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ និយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) និងនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) សម្រេចចេញគោលការណ៍ណែនាំរួមស្ដីពីការចុះបញ្ជី និងការស្នើសុំការអនុញ្ញាតបន្ថែមរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសនៃគម្រោងវិនិយោគរួម និងភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ ដូចខាងក្រោម៖

## ជំពូកទី១
## ការចុះបញ្ជីក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស និងភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ

### ១-ការដាក់ពាក្យស្នើសុំចុះបញ្ជី

បុគ្គលដែលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសពី **ន.ម.ភ.** ហើយទទួលបានការអនុញ្ញាតជាគោលការណ៍លើការស្នើសុំអាជ្ញាបណ្ណនេះពី **ន.ម.ភ.** ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីជាប្រតិបត្តិករបរធនបាលក្នុងវិស័យមូលបត្រនៅ **ន.ម.ឆ.** ទៅតាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃ **ន.ម.ឆ.** និងផ្តល់ឯកសារភ្ជាប់ដូចខាងក្រោម÷

ក- សេចក្តីចម្លងលិខិតអនុញ្ញាតជាគោលការណ៍លើការស្នើសុំអាជ្ញាបណ្ណក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសពី **ន.ម.ភ.**។

ខ- លក្ខន្តិកៈក្រុមហ៊ុនចុងក្រោយ។

បុគ្គលដែលទទួលបានអាជ្ញាបណ្ណក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសពី **ន.ម.ភ.** ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីជាប្រតិបត្តិករបរធនបាលក្នុងវិស័យមូលបត្រនៅ **ន.ម.ឆ.** ក្នុងរយៈពេលដូចដែលបានកំណត់នៅក្នុងប្រការ៧១ នៃប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច ទៅតាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃ **ន.ម.ឆ.** និងផ្តល់ឯកសារភ្ជាប់ដូចខាងក្រោម÷

ក- សេចក្តីចម្លងអាជ្ញាបណ្ណក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសដែលទទួលបានពី **ន.ម.ភ.** ដែលមានបញ្ជាក់ត្រឹមត្រូវ។

ខ- លក្ខន្តិកៈក្រុមហ៊ុនចុងក្រោយ។

បុគ្គលដែលបានដាក់ពាក្យស្នើសុំការទទួលស្គាល់ជាភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រពី **ន.ម.ភ.** ហើយទទួលបានការអនុញ្ញាតជាគោលការណ៍លើការស្នើសុំការទទួលស្គាល់នេះពី **ន.ម.ភ.** ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីជាបុគ្គលថែរក្សាសុវត្ថិភាពបរធនក្នុងវិស័យមូលបត្រនៅ **ន.ម.ឆ.** ទៅតាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃ **ន.ម.ឆ.** និងផ្តល់ឯកសារភ្ជាប់ដូចខាងក្រោម÷

ក- សេចក្តីចម្លងលិខិតអនុញ្ញាតជាគោលការណ៍លើការស្នើសុំការទទួលស្គាល់ជាភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រពី **ន.ម.ភ.**។

ខ- លក្ខន្តិកៈក្រុមហ៊ុនចុងក្រោយ។

បុគ្គលដែលទទួលបានការទទួលស្គាល់ជាភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រពី **ន.ម.ភ.** ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីជាបុគ្គលថែរក្សាសុវត្ថិភាពបរធនក្នុងវិស័យមូលបត្រនៅ **ន.ម.ឆ.** ក្នុងរយៈពេលដូចដែលបានកំណត់នៅក្នុងប្រការ៧១ នៃប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច ទៅតាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃ **ន.ម.ឆ.** និងផ្តល់ឯកសារភ្ជាប់ដូចខាងក្រោម÷

ក- សេចក្តីចម្លងវិញ្ញាបនបត្រទទួលស្គាល់ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រពី **ន.ម.ក.** ដែលមានបញ្ជាក់ត្រឹមត្រូវ។

ខ- លក្ខន្តិកៈក្រុមហ៊ុនចុងក្រោយ។

**២-សុពលភាពនៃការចុះបញ្ជី**

សុពលភាពនៃការចុះបញ្ជីជាប្រតិបត្តិករបរធនបាលក្នុងវិស័យមូលបត្រអនុលោមតាមគោលការណ៍ណែនាំរួមនេះ មានរយៈពេលមិនកំណត់ អនុលោមទៅតាមសុពលភាពនៃអាជ្ញាបណ្ណក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសពី **ន.ម.ក.**។

សុពលភាពនៃការចុះបញ្ជីជាបុគ្គលថែរក្សាសុវត្ថិភាពបរធនក្នុងវិស័យមូលបត្រអនុលោមតាមគោល-ការណ៍ណែនាំរួមនេះ មានរយៈពេលមិនកំណត់ អនុលោមទៅតាមសុពលភាពនៃការទទួលស្គាល់ជាភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រពី **ន.ម.ក.**។

**៣-ថ្លៃពាក្យស្នើសុំ សោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃចុះបញ្ជី**

បុគ្គលដែលដាក់ពាក្យស្នើសុំចុះបញ្ជីជាប្រតិបត្តិករបរធនបាលក្នុងវិស័យមូលបត្រ ឬជាបុគ្គលថែរក្សាសុវត្ថិភាពបរធនក្នុងវិស័យមូលបត្រ ត្រូវបង់ថ្លៃពាក្យស្នើសុំចំនួន ២០.០០០(ម្ភៃពាន់) រៀល និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ១.០០០.០០០(មួយលាន) រៀល នៅ **ន.ម.ឧ.** នៅពេលដាក់ពាក្យស្នើសុំ និងបង់ថ្លៃចុះបញ្ជីប្រចាំឆ្នាំចំនួន ៤.០០០.០០០ (បួនលាន) រៀល ដោយគិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជី។ សម្រាប់ឆ្នាំបន្ទាប់ បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់ថ្លៃចុះបញ្ជីប្រចាំឆ្នាំយ៉ាងយូរ ៣០(សាមសិប) ថ្ងៃ មុនថ្ងៃខែនៃការចុះបញ្ជី។

**៤-ការផ្អាក ឬលុបចោលការចុះបញ្ជី**

អគ្គនាយកនៃ **ន.ម.ឧ.** អាចផ្អាក ឬលុបចោលការចុះបញ្ជីជាប្រតិបត្តិករបរធនបាលក្នុងវិស័យមូលបត្រ ក្នុងករណីបុគ្គលដែលបានចុះបញ្ជីជាប្រតិបត្តិករបរធនបាលក្នុងវិស័យមូលបត្រស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោមៈ

ក- អគ្គនាយកនៃ **ន.ម.ក.** បានព្យួរ ឬលុបចោលការអនុញ្ញាតជាគោលការណ៍លើការស្នើសុំអាជ្ញាបណ្ណក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស។

ខ- អគ្គនាយកនៃ **ន.ម.ក.** បានផ្អាក ឬបញ្ឈប់ការធ្វើប្រតិបត្តិការអាជីវកម្មជាក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស។

គ- អគ្គនាយកនៃ **ន.ម.ក.** បានព្យួរ លុបចោល ឬដកហូតអាជ្ញាបណ្ណក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស។

ឃ- បុគ្គលដែលបានចុះបញ្ជីជាប្រតិបត្តិករបរធនបាលក្នុងវិស័យមូលបត្រមិនគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី៣ នៃជំពូកនេះ។

អគ្គនាយកនៃ **ន.ប.ឩ.** អាចផ្អាក ឬលុបចោលការចុះបញ្ជីជាបុគ្គលថែរក្សាសុវត្ថិភាពបរធនក្នុងវិស័យមូលបត្រ ក្នុងករណីបុគ្គលដែលបានចុះបញ្ជីជាបុគ្គលថែរក្សាសុវត្ថិភាពបរធនក្នុងវិស័យមូលបត្រស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម៖

ក- អគ្គនាយកនៃ **ន.ម.ភ.** បានព្យួរ ឬលុបចោលការអនុញ្ញាតជាគោលការណ៍លើការស្នើសុំការទទួលស្គាល់ជាភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ។

ខ- អគ្គនាយកនៃ **ន.ម.ភ.** បានផ្អាក ឬបញ្ឈប់ការធ្វើប្រតិបត្តិការអាជីវកម្មជាភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ។

គ- អគ្គនាយកនៃ **ន.ម.ភ.** បានព្យួរ លុបចោល ឬដកហូតការទទួលស្គាល់ជាភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ។

ឃ- បុគ្គលដែលបានចុះបញ្ជីជាបុគ្គលថែរក្សាសុវត្ថិភាពបរធនក្នុងវិស័យមូលបត្រមិនគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី៣ នៃជំពូកនេះ។

## ៥-កាតព្វកិច្ចជូនដំណឹងអំពីការផ្លាស់ប្តូរ ឬការកែប្រែព័ត៌មាន

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសដែលទទួលបានអាជ្ញាបណ្ណពី **ន.ម.ភ.** និងភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រដែលទទួលបានការទទួលស្គាល់ពី **ន.ម.ភ.** និងបានចុះបញ្ជីនៅ **ន.ប.ឩ.** អនុលោមតាមគោលការណ៍ណែនាំរួមនេះ ត្រូវជូនដំណឹងមក **ន.ប.ឩ.** អំពីការផ្លាស់ប្តូរ ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន រួមបញ្ចូលទាំងការផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល រចនាសម្ព័ន្ធភាគហ៊ុនិក ដើមទុន នាមករណ៍ និងទីស្នាក់ការ ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានការសម្រេចជាផ្លូវការពី **ន.ម.ភ.**។

## ៦-កាតព្វកិច្ចក្នុងប្រតិបត្តិការអាជីវកម្ម រក្សាកម្រិតស្ថានភាពហិរញ្ញវត្ថុ ផ្តល់របាយការណ៍ ជូនដំណឹង ស្នើសុំការអនុញ្ញាត និងប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈ

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសដែលទទួលបានអាជ្ញាបណ្ណពី **ន.ម.ភ.** និងភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រដែលទទួលបានការទទួលស្គាល់ពី **ន.ម.ភ.** និងបានចុះបញ្ជីនៅ **ន.ប.ឩ.** អនុលោមតាមគោលការណ៍ណែនាំរួមនេះ ត្រូវអនុវត្តកាតព្វកិច្ចក្នុងប្រតិបត្តិការអាជីវកម្ម រក្សាកម្រិតស្ថានភាពហិរញ្ញវត្ថុ ផ្តល់របាយការណ៍ ជូនដំណឹង ស្នើសុំការអនុញ្ញាត និងប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈ ក្រោមនិយ័តកម្មរបស់ **ន.ម.ភ.** អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាននៃវិស័យមូលបត្រ។

## ៧-ការត្រួតពិនិត្យ

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសដែលទទួលបានអាជ្ញាបណ្ណពី **ន.ម.ភ.** និងភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រដែលទទួលបានការទទួលស្គាល់ពី **ន.ម.ភ.** និងបានចុះបញ្ជីនៅ **ន.ប.ឩ.** ត្រូវស្ថិតក្រោម

ការត្រួតពិនិត្យ រួមបញ្ចូលទាំងការចុះត្រួតពិនិត្យដល់ទីកន្លែងក្រោមនិយ័តកម្មរបស់ **ន.ម.ក.** អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាននៃវិស័យមូលបត្រ។

## ជំពូកទី២
## ការស្នើសុំការអនុញ្ញាតបន្ថែម

### ១-ការស្នើសុំការអនុញ្ញាតបន្ថែមពី ន.ប.ធ.

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសទទួលបានអាជ្ញាបណ្ណពី **ន.ម.ក.** ដែលមានបំណងធ្វើប្រតិបត្តិការបរធនបាលកិច្ចផ្សេងក្រៅពីគម្រោងវិនិយោគរួមនៅក្នុងវិស័យមូលបត្រ ដូចមានចែងក្នុងប្រការ១៤ នៃប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច ត្រូវស្នើសុំការអនុញ្ញាតបន្ថែមពី **ន.ប.ធ.** និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

ក- ដាក់ពាក្យស្នើសុំមក **ន.ប.ធ.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់តាមការកំណត់របស់អគ្គនាយកនៃ **ន.ប.ធ.**។

ខ- ផ្តល់លិខិត "មិនជំទាស់" ពី **ន.ម.ក.** ចំពោះការស្នើសុំការអនុញ្ញាតបន្ថែម។

គ- បំពេញមូលធនអប្បបរមាបន្ថែមលើមូលធនអប្បបរមាដែលតម្រូវដោយ **ន.ម.ក.** សម្រាប់ការស្នើសុំការអនុញ្ញាតបន្ថែមធ្វើប្រតិបត្តិការបរធនបាលកិច្ចសាធារណៈ។ ដើម្បីបង្កើនមូលធនអប្បបរមាដូចមានចែងក្នុងចំណុចនេះ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសត្រូវស្នើសុំការអនុញ្ញាតជាមុនពី **ន.ម.ក.** អនុលោមតាមប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម។

ឃ- ដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១៥ (ដប់ប្រាំ) ភាគរយ នៃមូលធនអប្បបរមារបស់ក្រុមហ៊ុនក្នុងគណនីរបស់ **ន.ប.ធ.** នៅធនាគារជាតិនៃកម្ពុជា និងត្រូវរក្សាឱ្យបានគ្រប់ពេលវេលានូវមូលធនភាគហ៊ុនិកយ៉ាងតិចស្មើនឹងមូលធនអប្បបរមារបស់ក្រុមហ៊ុន អនុលោមតាមចំណុចទី៣ នៃប្រការ ១៦ នៃប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច។

ង- មិនតម្រូវឱ្យមានអភិបាល នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ និងគណនេយ្យករមានជំនាញបរធនដាច់ដោយឡែកពីបុគ្គលដែលទទួលបានការទទួលស្គាល់គុណវុឌ្ឍិពី **ន.ម.ក.** នោះទេ ដែលក្នុងនោះគណនេយ្យករជំនាញមូលនិធិអាចទទួលបន្ទុកបន្ថែមជាគណនេយ្យករមានជំនាញបរធន។ បុគ្គលដែលទទួលបានការទទួលស្គាល់គុណវុឌ្ឍិពី **ន.ម.ក.** ទាំងនេះត្រូវចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡង ដែលរៀបចំដោយ **ន.ប.ធ.** ឬដោយស្ថាប័នបណ្តុះបណ្តាលទទួលបានសិទ្ធិពី **ន.ប.ធ.** និងត្រូវចូលរួមការអប់រំវិជ្ជាជីវៈបន្ត មុនពេលលទ្ធផលប្រឡងអស់សុពលភាព។

ច- មានបរធនបាលរូបវន្តបុគ្គលអនុលោមតាមចំណុច៤-ខ នៃប្រការ១៦ នៃប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច ដែលត្រូវតែជាបុគ្គលដាច់ដោយ-ឡែកពីបុគ្គលដែលត្រូវទទួលស្គាល់គុណវុឌ្ឍិពី **ន.ម.ភ.**។

ឆ- បំពេញលក្ខខណ្ឌដូចមានកំណត់ក្នុងចំណុចទី៦ ដល់ចំណុចទី១៣ នៃកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃប្រការ១៦ នៃប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធន-បាលកិច្ច។

ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រទទួលបានការទទួលស្គាល់ពី **ន.ម.ភ.** ដែលមានបំណងធ្វើប្រតិបត្តិការរក្សាសុវត្ថិភាពបរធនបាលកិច្ចផ្សេងក្រៅពីវិស័យមូលបត្រដូចមានចែងក្នុងប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច ត្រូវស្នើសុំការអនុញ្ញាតបន្ថែមពី **ន.ប.ធ.** និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

ក- ដាក់ពាក្យស្នើសុំមក **ន.ប.ធ.** ទៅតាមទម្រង់ និងឯកសារភ្ជាប់តាមការកំណត់របស់អគ្គនាយកនៃ **ន.ប.ធ.**។

ខ- ផ្តល់លិខិត “មិនជំទាស់” ពី **ន.ម.ភ.** ចំពោះការស្នើសុំការអនុញ្ញាតបន្ថែម។

គ- មិនតម្រូវឱ្យបំពេញមូលធនអប្បបរមាបន្ថែមលើមូលធនអប្បបរមាដែលតម្រូវដោយ **ន.ម.ភ.** នោះទេ ប៉ុន្តែត្រូវដាក់បន្ថែមប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១៥ (ដប់ប្រាំ) ភាគរយនៃមូលធនអប្បបរមារបស់ខ្លួន ក្នុងគណនីរបស់ **ន.ប.ធ.** នៅធនាគារជាតិនៃកម្ពុជា និងត្រូវរក្សាឱ្យបានគ្រប់ពេលវេលានូវមូលធនភាគហ៊ុនិកយ៉ាងតិចស្មើនឹងមូលធនអប្បបរមារបស់ក្រុមហ៊ុន អនុលោមតាមចំណុចទី៣ នៃប្រការ១៦ នៃប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធន-បាលកិច្ច។

ឃ- មិនតម្រូវឱ្យមានប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ និងគណនេយ្យករមានជំនាញបរធនដាច់ដោយឡែកពីបុគ្គលដែលបានទទួលស្គាល់ការតែងតាំងពី **ន.ម.ភ.** នោះទេ ដែលក្នុងនោះប្រធានទទួលបន្ទុកផ្នែកហិរញ្ញវត្ថុអាចទទួលបន្ទុកបន្ថែមជាគណនេយ្យករមានជំនាញបរធន។ បុគ្គលដែលបានទទួលស្គាល់ការតែងតាំងពី **ន.ម.ភ.** ត្រូវចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡង ដែលរៀបចំដោយ **ន.ប.ធ.** ឬដោយស្ថាប័នបណ្តុះបណ្តាលទទួលបានសិទ្ធិពី **ន.ប.ធ.** និងត្រូវចូលរួមការអប់រំវិជ្ជាជីវៈបន្ត មុនពេលលទ្ធផលប្រឡងអស់សុពលភាព។

ង- បំពេញលក្ខខណ្ឌដូចមានកំណត់ក្នុងចំណុចទី៦ ដល់ចំណុចទី១៣ នៃកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃប្រការ១៦ នៃប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធន-បាលកិច្ច។

ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រជាធនាគារពាណិជ្ជ ដែលស្នើសុំការអនុញ្ញាតបន្ថែមធ្វើប្រតិបត្តិការរក្សាសុវត្ថិភាពបរធនបាលកិច្ចផ្សេងក្រៅពីវិស័យមូលបត្រ មិនតម្រូវឱ្យបំពេញលក្ខខណ្ឌតម្រូវដាក់បន្ថែមប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១៥ (ដប់ប្រាំ) ភាគរយនៃមូលធនអប្បបរមានោះទេ។

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធក្នុងការផ្តល់ការអនុញ្ញាត ឬបន្តការអនុញ្ញាត ប្រសិនបើបុគ្គលដាក់ពាក្យស្នើសុំមិនអាចបំពេញលក្ខខណ្ឌតម្រូវ អនុលោមតាមចំណុចទី១ នៃជំពូកទី២ នេះ និងប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច។

## ២-សុពលភាពនៃការអនុញ្ញាត

ការអនុញ្ញាតធ្វើប្រតិបត្តិការបរធនបាលកិច្ចផ្សេងក្រៅពីគម្រោងវិនិយោគរួម ឬប្រតិបត្តិការរក្សាសុវត្ថិភាពបរធនបាលកិច្ចផ្សេងក្រៅពីវិស័យមូលបត្រស្របតាមគោលការណ៍ណែនាំរួមនេះ មានសុពលភាព ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទទទួលបានការអនុញ្ញាត។

ការអនុញ្ញាតបន្តធ្វើប្រតិបត្តិការទាំងនេះ មានសុពលភាព ៣ (បី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទការអនុញ្ញាតចាស់ផុតសុពលភាព។

## ៣-ថ្លៃពាក្យស្នើសុំ សោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃការអនុញ្ញាត

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសដែលដាក់ពាក្យស្នើសុំការអនុញ្ញាតបន្ថែមធ្វើប្រតិបត្តិការបរធនបាលកិច្ចផ្សេងក្រៅពីគម្រោងវិនិយោគរួម ត្រូវបង់ថ្លៃពាក្យស្នើសុំ សោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃការអនុញ្ញាត ទៅតាមករណីដូចខាងក្រោម៖

ក-ចំពោះការស្នើសុំការអនុញ្ញាត/បន្តការអនុញ្ញាតបន្ថែម៖

- ថ្លៃពាក្យស្នើសុំការអនុញ្ញាតចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់
- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ២.០០០.០០០ (ពីរលាន) រៀល
- ថ្លៃការអនុញ្ញាត៖
  - សម្រាប់ប្រតិបត្តិការលើបរធនបាលកិច្ចសាធារណៈ ចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និង ២៤.០០០.០០០ (ម្ភៃបួនលាន) រៀល សម្រាប់ការអនុញ្ញាតបន្តរយៈពេល ៣ (បី) ឆ្នាំ
  - សម្រាប់ប្រតិបត្តិការលើបរធនបាលកិច្ចពាណិជ្ជកម្ម ចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និង ១៨.០០០.០០០ (ដប់ប្រាំបីលាន) រៀល សម្រាប់ការអនុញ្ញាតបន្តរយៈពេល ៣ (បី) ឆ្នាំ

- សម្រាប់ប្រតិបត្តិការលើបរធនបាលកិច្ចសង្គម ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និង ១២.០០០.០០០ (ដប់ពីរលាន) រៀល សម្រាប់ការអនុញ្ញាតបន្តរយៈពេល ៣ (បី) ឆ្នាំ
- សម្រាប់ប្រតិបត្តិការលើបរធនបាលកិច្ចបុគ្គល ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និង ១២.០០០.០០០ (ដប់ពីរលាន) រៀល សម្រាប់ការអនុញ្ញាតបន្តរយៈពេល ៣ (បី) ឆ្នាំ។

ខ-ចំពោះការស្នើសុំអាជ្ញាបណ្ណ/ បន្តអាជ្ញាបណ្ណធ្វើជាបរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាលៈ

- ថ្លៃពាក្យស្នើសុំអាជ្ញាបណ្ណចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់
- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ៤០០.០០០ (បួនរយពាន់) រៀល
- ថ្លៃអាជ្ញាបណ្ណចំនួន ២.០០០.០០០ (ពីរលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និង ថ្លៃបន្តអាជ្ញាបណ្ណចំនួន ៣.០០០.០០០ (បីលាន) រៀល សម្រាប់រយៈពេល ៣ (បី) ឆ្នាំ។

ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រដែលដាក់ពាក្យស្នើសុំការអនុញ្ញាតបន្ថែមធ្វើប្រតិបត្តិការរក្សាសុវត្ថិភាពបរធនបាលកិច្ចផ្សេងក្រៅពីវិស័យមូលបត្រ ត្រូវបង់ថ្លៃពាក្យស្នើសុំ សោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃការអនុញ្ញាត ទៅតាមករណីដូចខាងក្រោមៈ

ក-ចំពោះការស្នើសុំការអនុញ្ញាត/បន្តការអនុញ្ញាតបន្ថែមៈ

- ថ្លៃពាក្យស្នើសុំការអនុញ្ញាតចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់
- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ២.០០០.០០០ (ពីរលាន) រៀល
- ថ្លៃការអនុញ្ញាតៈ
  - សម្រាប់ប្រតិបត្តិការថែរក្សាសុវត្ថិភាពបរធននៃបរធនបាលកិច្ចសាធារណៈ ចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និង ២៤.០០០.០០០ (ម្ភៃបួនលាន) រៀល សម្រាប់ការអនុញ្ញាតបន្តរយៈពេល ៣ (បី) ឆ្នាំ
  - សម្រាប់ប្រតិបត្តិការថែរក្សាសុវត្ថិភាពបរធននៃបរធនបាលកិច្ចពាណិជ្ជកម្ម ចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និង ១៨.០០០.០០០ (ដប់ប្រាំបីលាន) រៀល សម្រាប់ការអនុញ្ញាតបន្តរយៈពេល ៣ (បី) ឆ្នាំ
  - សម្រាប់ប្រតិបត្តិការថែរក្សាសុវត្ថិភាពបរធននៃបរធនបាលកិច្ចសង្គម ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និង ១២.០០០.០០០ (ដប់ពីរលាន) រៀល សម្រាប់ការអនុញ្ញាតបន្តរយៈពេល ៣ (បី) ឆ្នាំ

- សម្រាប់ប្រតិបត្តិការថែរក្សាសុវត្ថិភាពបរធននៃបរធនបាលកិច្ចបុគ្គល ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និង ១២.០០០.០០០ (ដប់ពីរលាន) រៀល សម្រាប់ការអនុញ្ញាតបន្តរយៈពេល ៣ (បី) ឆ្នាំ។

បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត នៅពេលដាក់ពាក្យស្នើសុំនៅ **ន.ម.ឥ.**។

ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំលិខិតអនុលោមតាមចំណុចនេះ មិនត្រូវបានប្រគល់ឱ្យបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីជាការស្នើសុំត្រូវបានបដិសេធក៏ដោយ។

## ៤-កាតព្វកិច្ចក្នុងប្រតិបត្តិការអាជីវកម្ម រក្សាកម្រិតស្ថានភាពហិរញ្ញវត្ថុ ផ្តល់របាយការណ៍ ជូនដំណឹង ស្នើសុំការអនុញ្ញាត និងប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈ

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស និងភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ ដែលទទួលបានការអនុញ្ញាតបន្ថែមពី **ន.ម.ឥ.** អនុលោមតាមគោលការណ៍ណែនាំរួមនេះ ត្រូវអនុវត្តកាតព្វកិច្ចក្នុងប្រតិបត្តិការអាជីវកម្ម រក្សាកម្រិតស្ថានភាពហិរញ្ញវត្ថុ ផ្តល់របាយការណ៍ ជូនដំណឹង ស្នើសុំការអនុញ្ញាត និងប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈក្រោមនិយ័តកម្មដាច់ដោយឡែកពីគ្នារបស់ **ន.ម.ភ.** និង **ន.ម.ឥ.** អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។

## ៥-ការញែកឱ្យដាច់ដោយឡែកពីគ្នា

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសដែលទទួលបានការអនុញ្ញាតបន្ថែមពី **ន.ម.ឥ.** អនុលោមតាមគោលការណ៍ណែនាំរួមនេះ ត្រូវញែកឱ្យដាច់ដោយឡែកពីគ្នានូវប្រតិបត្តិការក្រុមហ៊ុន និងបរធនវិនិយោគក្រោមគម្រោងវិនិយោគរួម ពីប្រតិបត្តិការបរធនបាលកិច្ច និងទ្រពសម្បត្តិបរធនបាលកិច្ចក្រៅពីគម្រោងវិនិយោគរួម។

ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រដែលទទួលបានការអនុញ្ញាតបន្ថែមពី **ន.ម.ឥ.** អនុលោមតាមគោលការណ៍ណែនាំរួមនេះ ត្រូវញែកឱ្យដាច់ដោយឡែកពីគ្នានូវប្រតិបត្តិការរបស់ខ្លួន និងទ្រព្យសម្បត្តិក្រោមគណនីរក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ ពីប្រតិបត្តិការថែរក្សាសុវត្ថិភាពបរធន និងទ្រព្យសម្បត្តិក្រោមគណនីរក្សាសុវត្ថិភាពក្រៅពីវិស័យមូលបត្រ។

## ៦-ការធ្វើ និងរក្សាទុកកំណត់ត្រា

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស និងភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ ដែលទទួលបានការអនុញ្ញាតបន្ថែមពី **ន.ម.ឥ.** អនុលោមតាមគោលការណ៍ណែនាំរួមនេះ ត្រូវធ្វើ និងរក្សាទុកកំណត់ត្រា ឯកសារ ទិន្នន័យ និងបញ្ជីការគណនេយ្យ សម្រាប់អាជីវកម្មនីមួយៗដាច់ដោយឡែកពីគ្នា អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។

**៧-ការត្រួតពិនិត្យ**

ក្រុមហ៊ុនថៃរក្សាទ្រព្យសម្បត្តិជំនួស និងភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ ដែលទទួលបានការអនុញ្ញាតបន្ថែមពី **ន.ប.ធ.** អនុលោមតាមគោលការណ៍ណែនាំរួមនេះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យ រួមបញ្ចូលទាំងការចុះត្រួតពិនិត្យដល់ទីកន្លែងក្រោមនិយ័តកម្មដាច់ដោយឡែកពីគ្នារបស់ **ន.ម.ក.** និង **ន.ប.ធ.** អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។

ក្នុងករណីក្រុមហ៊ុនថៃរក្សាទ្រព្យសម្បត្តិជំនួស និងភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ ដែលទទួលបានការអនុញ្ញាតបន្ថែមពី **ន.ប.ធ.** អនុលោមតាមគោលការណ៍ណែនាំរួមនេះ ស្នើសុំផ្អាក ឬឈប់ធ្វើអាជីវកម្ម ឬត្រូវទទួលរងវិធានការរដ្ឋបាលឬការផាកពិន័យពី **ន.ម.ក.** ឬ **ន.ប.ធ.** **ន.ម.ក.** និង **ន.ប.ធ.** ត្រូវពិនិត្យ និងសហការផ្លាស់ប្ដូរព័ត៌មានគ្នាជាមុន ដើម្បីការពារផលប្រយោជន៍របស់អតិថិជន និង/ ឬ អត្ថគាហកៈ។

| | |
|---|---|
| **និយ័តករមូលបត្រកម្ពុជា** | **និយ័តករបរធនធានកិច្ច** |